# មេរៀនទី២៧៖ អ័ប្រាហាំស្ដាប់បង្គាប់ព្រះ

## លោកុប្បត្តិ ២២៖១-១៨

**មេរៀនសម្រាប់គ្រូ** *(យូធូបលីង)*៖ https://youtu.be/xe95tuUQnFE

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/ptoryjNnqLQ

**គោលបំណង៖** ចង់ឲ្យកុមារៗទុកចិត្ត ហើយស្តាប់បង្គាប់ព្រះ

**ខគម្ពីរចងចាំ៖ ចោទិយកថា ៦៖១៨** *" ក៏ត្រូវតែប្រព្រឹត្តការទៀងត្រង់ ហើយល្អនៅព្រះនេត្ររបស់ ព្រះយេហូវ៉ា ។"*

**ចំរៀង** *(យូធូបលីង)*៖

១. លោកតាអ័ប្រាហាំ https://youtu.be/OAuJ7i82odA

២. ខ្ញុំទុកចិត្តលើព្រះយេស៊ូវ https://youtu.be/Vq_yln2huAM

៣. កូនតូចៗអើយ https://youtu.be/ewu6Tfpo5Vo

### ១. អធិស្ឋាន

### ២. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

### ៣. ល្បែងកំសាន្ត

**ល្បែងកំសាន្តទី១** (ស្តេចបញ្ជា - សំរាប់កូនក្មេង ឬកុមារវ័យជំទង់)

**របៀបលេង៖**

- យើងលេងល្បែងស្តេចបញ្ជាដោយគ្រូដើរតួធ្វើជាស្តេច នៅពេលដែលកុមារឮពាក្យ "ស្តេចបញ្ជា "
- កុមារត្រូវធ្វើតាមអ្វីដែលគ្រូបានប្រាប់ដូចជា ប៉ះក្បាល លោតឡើង ឬ សើច...។
- បើអត់ ឮពាក្យ "ស្តេចបញ្ជា " កុមារមិនត្រូវធ្វើតាមនោះទេ។
- ពេលខ្លះគ្រូអាចធ្វើបន្លំ ឲ្យកុមារធ្វើខុសតាមដែរ ដោយគ្រូធ្វើកាយវិការតែអត់ស្រែកថា "ស្តេចបញ្ជា " ទេ។

**ល្បែងកំសាន្តទី២ (សំរាប់ក្មេងជំទង់)**



- បិទភ្នែកកុមារម្នាក់ (អាចយកក្រមា ឬ ក្រណាត់មករុំភ្នែករបស់គាត់)។
- ហើយយកស្ករគ្រាប់ទៅបិទលើជញ្ជាំងដែលនៅឆ្ងាយពីកុមារម្នាក់នោះដោយមិនប្រាប់គាត់ថាជារបស់អ្វីឡើយ(អាចយកស្ករមកប្រើ)។
- ឲ្យកុមារម្នាក់ទៀត(មិនបិទភ្នែក) ប្រាប់កុមារដែលបិទភ្នែកនោះពីទិសដៅទៅរកស្ករគ្រាប់នោះ
- គ្រូត្រូវប្រាប់កុមារដែលត្រូវគេបិទភ្នែកនោះថា គាត់ត្រូវទុកចិត្តលើការបង្ហាញណែនាំពីដៃគូ របស់ពួកគេ
- ហើយឲ្យគាត់ស្តាប់តាម ទោះជាគាត់មិនយល់ពីមូលហេតុអ្វីក៏ដោយ។

- ពួកគាត់មានពេល១នាទី ដើម្បីស្វែងរកស្ករគ្រាប់ឲ្យឃើញ។

(បន្ទាប់ពីលែងល្បែងចប់) ត្រូវចាំថាតើវាសំខាន់ប៉ុណ្ណាសំរាប់កុមារដែលត្រូវគេបិទភ្នែកត្រូវស្តាប់ហើយធ្វើតាមដៃគូរបស់គេ។ វាស្រដៀងនឹងការដែលយើងស្តាប់បង្គាប់ព្រះដែរ ព្រះមានហេតុផលសម្រាប់គ្រប់យ៉ាងទ្រង់ឲ្យយើងគ្រប់គ្នាស្តាប់បង្គាប់ទ្រង់ ទោះបីជាយើងអាចនឹងមិនដឹងថាព្រះមានបំណងអ្វីក៏ដោយ តែយើងអាចទុកចិត្តទ្រង់បាន យើងអាចដឹងថានៅពេលដែលយើងស្តាប់បង្គាប់ព្រះ រឿងល្អៗនឹងកើតមានឡើងទោះជាយើងអាចនឹងមើលមិនឃើញហេតុផលពេលហ្នឹងក៏ដោយ។

## ៤. ការណែនាំមេរៀន

ថ្ងៃនេះយើងនឹងរៀនពីអ័ប្រាហាំជាអ្នកដែលបានធ្វើឲ្យព្រះទ័យរបស់ព្រះ អរសប្បាយតាមរយៈការស្តាប់បង្គាប់។ ការស្តាប់បង្គាប់គឺមានន័យថា យើងទុកចិត្តព្រះនូវអ្វីដែលព្រះអង្គមានបន្ទូលឲ្យយើងធ្វើ ហើយយើងធ្វើដោយក្តីអំណរចេញពីចិត្ត។ ពេលខ្លះយើងមិនចូលចិត្តធ្វើអ្វីដែលអ្នកដទៃប្រាប់យើងឲ្យធ្វើទេ។ តើមានកូនៗប៉ុន្មាននាក់ដែលស្តាប់បង្គាប់ឪពុកម្តាយរបស់កូនៗ ពេលពួកគាត់ប្រាប់ឲ្យយើងធ្វើអ្វីមួយ? ហើយមានកូនៗប៉ុន្មាននាក់ដែលមិនស្តាប់តាមឪពុកម្តាយ? ថ្ងៃនេះយើងនឹងរៀនជាមួយគ្នាថាតើលោកអ័ប្រាហាំស្តាប់បង្គាប់ព្រះដោយរបៀបណាដែលធ្វើ ឲ្យព្រះសព្វព្រះទ័យ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

អ័ប្រាហាំគឺជាគំរូមួយដ៏អស្ចារ្យសំរាប់យើងគ្រប់គ្នាដែលទុកចិត្ត និងស្តាប់បង្គាប់ទ្រង់។ ព្រះបានសន្យាជាមួយអ័ប្រាហាំថាគាត់នឹងមានកូនចៅជាច្រើន គឺច្រើនជាងផ្កាយនៅលើមេឃ ប៉ុន្តែអ័ប្រាហាំមានកូនប្រុសដំបូងរបស់គាត់ឈ្មោះអ៊ីសាកនៅពេលដែលគាត់ចាស់ណាស់ទៅហើយ គឺនៅពេលដែលគាត់មានអាយុ ១០០ឆ្នាំ។ តើព្រះអាចរក្សាការសន្យារបស់ទ្រង់បានទេ បើអ័ប្រាហាំ មានអាយុចាស់ណាស់ទៅហើយ ហើយទើបតែមានកូនប្រុសតែម្នាក់ដូច្នេះ?

មុនពេលព្រះប្រទានពរឲ្យអ័ប្រាហាំមានកូនចៅច្រើនដូចជាផ្កាយនៅលើមេឃ អ័ប្រាហាំត្រូវស្តាប់បង្គាប់ព្រះជាមុនសិន ព្រះមានបន្ទូលទៅអ័ប្រាហាំឲ្យថ្វាយអ៊ីសាកនៅពេលដែល អ៊ីសាកនៅជាក្មេង តូចនៅឡើយ។ ការថ្វាយនេះមានន័យថា គឺសំលាប់អ៊ីសាក យើងពិបាកយល់ពីហេតុផលរបស់ព្រះថា ហេតុអ្វីបានជាទ្រង់បង្គាប់ឲ្យអ័ប្រាហាំធ្វើបែបនេះ តែអ័ប្រាហាំនៅតែទុកចិត្តព្រះ ហើយធ្វើតាមការបង្គាប់បញ្ជារបស់ទ្រង់។

អ័ប្រាហាំបាននាំអ៊ីសាកឡើងទៅលើភ្នំម៉ូរីយ៉ាជាកន្លែង ដែលព្រះបានបង្គាប់គាត់ឲ្យទៅអ័ប្រាហាំ បានរៀប-ចំដើម្បីធ្វើការថ្វាយអ៊ីសាកដល់ទ្រង់ខណៈពេលដែលអ័ប្រាហាំរៀបចំបូជាយញ្ញនោះ ព្រះបានឃាត់ អ័ប្រាំ-ហាំហើយប្រាប់គាត់មិនឲ្យធ្វើបាបក្មេងនោះឡើយ ព្រះជ្រាបដឹងយ៉ាងច្បាស់ថា អ័ប្រាហាំស្រលាញ់ព្រះ ជាជាងរបស់គ្រប់យ៉ាង ហើយមិនថាមានរឿងអ្វីក៏ដោយក៏អ័ប្រាហាំស្តាប់បង្គាប់ ព្រះជានិច្ច។ អ៊ីសាកបង្កើតបានកូនចៅជាច្រើនរហូតដល់អ័ប្រា ហាំមានកូនចៅជាច្រើនដូចជា ផ្កាយនៅលើមេឃ។

ត្រូវចាំថា ព្រះទ្រង់មិនចង់យករបស់ជាទីស្រលាញ់របស់ប្អូនៗចេញពីប្អូនៗទេ តែព្រះអង្គចង់ឲ្យប្អូនៗស្រឡាញ់ទ្រង់ជាទី ១ នៅក្នុងចិត្តដូចអ្វីដែលអ័ប្រាហាំបានធ្វើ។

## ៦. សំនួរពិភាក្សា

១. តើអ្នកគិតថាហេតុអ្វីបានជាអ័ប្រាហាំស្តាប់តាមការបង្គាប់ របស់ព្រះដោយយកអ៊ីសាកធ្វើជាយញ្ញបូជា? (*ចម្លើយ៖ អ័ប្រាហាំទុកចិត្តព្រះ អ័ប្រាហាំដឹងថាព្រះជ្រាបដឹងថាអ្វីដែលល្អវិសេសសំរាប់គាត់*)

២. តើយើងបានរៀនអ្វីខ្លះពីអ័ប្រាហាំក្នុងការស្តាប់បង្គាប់ព្រះ? (*ចំលើយ: យើងត្រូវតែស្តាប់បង្គាប់ព្រះ មិនថាការបង្គាប់បញ្ជារនោះចំលែកយ៉ាងណាក៏ដោយ យើងនៅតែអាចទុកចិត្តព្រះនៅពេលដែលយើងស្តាប់បង្គាប់ទ្រង់*)

## ៧. ខគម្ពីរចងចាំ

**ចោទិយកថា ៦៖១៨** *"ក៏ត្រូវតែប្រព្រឹត្តការទៀងត្រង់ ហើយល្អនៅព្រះនេត្ររបស់ព្រះយេហូវ៉ា"* ។

សូមជួយសិស្សចងចាំខគម្ពីរនេះ ៖

- ➔ ចែកខគម្ពីរខាងលើជា៤ផ្នែកហើយសរសេរនៅលើផ្ទាំងក្រដាសផ្សេងៗគ្នា
- ➔ ចែកកុមារជា៣ឬ៤ក្រុម ហើយឲ្យក្រុមនីមួយៗឈរនៅជ្រុងម្ខាងៗ
- ➔ នៅពេលគ្រូស្រែកឲ្យក្រុមនីមួយៗ ត្រូវតែប្តូរកន្លែងគ្នាឈរ
- ➔ ឲ្យក្រុមដែលប្តូរកន្លែងរួចអានខគម្ពីរដែលនៅលើផ្ទាំងនោះ(ចាប់តាំងពីផ្ទាំងទី១ដល់ទី៤ឲ្យ ឮៗ)
- ➔ គ្រូអាចនាំកុមារលេងហ្គេមនេះរហូតដល់កុមារចងចាំខគម្ពីរនេះបាន។

## ៨. ហាត្ថកម្ម

**ហត្ថកម្មទី១៖** យើងអាចកាត់មួកពីក្រដាសកាតុងឬក្រដាសផ្សេងដែលវែង ហើយអាចបត់ធ្វើជារង្វង់មូលដែលអាចពាក់លើក្បាលបាន ហើយឲ្យកុមារផាត់ពណ៌វាឲ្យស្អាត។ ដើម្បីឆ្លើយតបទៅនឹងមេរៀនឱ្យកុមារសរសេរឈ្មោះកុមារ កណ្ដាលមួករបស់ពួកគេ។ វាជាការរំលឹកឲ្យគេស្តាប់បង្គាប់ ឬការប្តេជ្ញាចិត្តនឹងធ្វើឲ្យបាន។ ចុងក្រោយយើងកិបក្រដាសវែងនោះឲ្យប៉ុននិងទំហំក្បាលកុមារ។

ឧទាហរណ៍៖ ការប្តេជ្ញាចិត្តនឹងធ្វើឲ្យបាន កុមារសរសេរ: "សុខខឿន ស្តាប់បង្គាប់ព្រះអង្គ" ។






**ហត្ថកម្មៈទី២.**កុមារអាចផាត់ពណ៌រូបភាពដែលមាននៅលើទំព័រខាងក្រោមនេះ។

## ៩. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

## ១០. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
អ័ប្រាហាំបានស្តាប់បង្គាប់ព្រះ ព្រោះអ័ប្រាហាំទុកចិត្តព្រះ។ តើព្រះបានប្រាប់អ្នកឲ្យថ្វាយអ្វីសំរាប់ទ្រង់? អរព្រះគុណព្រះដែលទ្រង់បានជួយអ្នកឲ្យទុកចិត្តនិងស្តាប់បង្គាប់ទ្រង់។ពេលដែលយើងបន្តស្តាប់បង្គាប់ព្រះដូច អ័ប្រាហាំបានធ្វើ សេចក្តីជំនឿយើងនឹងរីកចំរើន ហើយទំនាក់ទំនងយើងជាមួយព្រះរាជបុត្រាព្រះយេស៊ូវគ្រីស្ទក៏រីកចំរើនដែរ។

# អ័ប្រាហាំស្តាប់បង្គាប់ព្រះ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

# អ័ប្រាហាំស្តាប់បង្គាប់ព្រះ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________